ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន
## កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន លើកទី២៤
## និងកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន លើកទី៣០
នៅថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ

នៅថ្ងៃទី ៤ ខែតុលា ឆ្នាំ២០២១ តបតាមការអញ្ជើញរបស់ **ឯកឧត្តម ដាតូ អ៊ីរ៉ាវ៉ាន់ ពើហ៊ីន យូស៊ូហ៍** រដ្ឋមន្ត្រីការបរទេសទី២ របស់ប្រទេសព្រុយណេដារ៉ូស្សាឡាម **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ានលើកទី២៤ និងកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន លើកទី៣០ តាមប្រព័ន្ធវីដេអូ ។

### កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ានលើកទី២៤ (24th APSC)

កិច្ចប្រជុំបានផ្លាស់ប្តូរទស្សនៈគ្នាលើការវិវត្តថ្មីៗនៃការងាររបស់ស្ថាប័នតាមវិស័យនៅក្នុងសសរស្តម្ភនយោបាយ និងសន្តិសុខ (APSC) និងបានស្វាគមន៍ចំពោះវឌ្ឍនភាពសំខាន់ៗដែលសម្រេចបាននៅក្នុងការអនុវត្តផែនការលម្អិត APSC ឆ្នាំ២០២៥ ទោះបីមានការរាំងស្ទះដោយជំងឺកូវីដ-១៩ ក៏ដោយ។ កិច្ចប្រជុំបានឯកភាពដាក់របាយការណ៍របស់កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ានលើកទី២៤ ជូនកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៨ និង លើកទី៣៩ ដើម្បីធ្វើការកត់សម្គាល់។ ក្នុងដំណើរឆ្ពោះទៅមុខ រដ្ឋមន្ត្រីការបរទេសអាស៊ាន បានគូសបញ្ជាក់អំពីសារៈសំខាន់ក្នុងការអនុវត្តការងារដែលនៅសេសសល់ ស្ថិតក្រោមផែនការលម្អិត APSC នេះ ដើម្បីធានាបាននូវដំណើរការកសាងសហគមន៍អាស៊ានប្រកបដោយប្រសិទ្ធភាព។

រដ្ឋមន្ត្រីក៏បានលើកឡើងផងដែរអំពីបញ្ហានានាជាចំណាប់អារម្មណ៍ និងកង្វល់រួមគ្នា ដែលមានសារៈសំខាន់ចំពោះសន្តិភាព សន្តិសុខ និងស្ថិរភាពនៅក្នុងតំបន់។ រដ្ឋមន្ត្រីអាស៊ានបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តដ៏រឹងមាំរបស់អាស៊ាន ដើម្បីថែរក្សាឱ្យបានមជ្ឈភាព និងឯកភាពរបស់អាស៊ាននៅក្នុងយន្តការនានា ដែលដឹកនាំដោយអាស៊ាន និងលើកកម្ពស់ជំនឿទុកចិត្តរវាងអាស៊ាន និងដៃគូខាងក្រៅ។ កិច្ចប្រជុំក៏បានឯកភាពគ្នាផងដែរធ្វើការលើកទឹកចិត្តឱ្យយុវជន និងស្ត្រីចូលរួមកាន់តែទូលំទូលាយ នៅក្នុងការកសាងសន្តិភាព និងសន្តិសុខ។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានចូលរួមជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានដទៃទៀត អបអរសាទរចំពោះវឌ្ឍនភាពនានាដែលសម្រេចបាននៅក្នុងការអនុវត្តផែនការលម្អិត APSC។ **ឯកឧត្តម** បានសម្តែងនូវក្តីបារម្ភថា ការកើនឡើងនូវភាពតានតឹងភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងរវាងប្រទេសមហាអំណាច អាចនឹងជំរុញឱ្យមានការរត់ប្រណាំងសព្វាវុធ និងបង្កអស្ថិរភាពដល់សន្តិភាពក្នុងតំបន់។ ក្នុងន័យនេះ **ឯកឧត្តម** បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការថែរក្សាឱ្យបាននូវគោលការណ៍នានារបស់អាស៊ានក្នុងការរក្សាបានតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ និងការចុះហត្ថលេខាលើពិធីសារចំពោះសន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ) ដោយប្រទេសដែលមានអាវុធនុយក្លេអ៊ែរទាំងប្រាំ។ **ឯកឧត្តម** បានជម្រាបជូនកិច្ចប្រជុំអំពីកម្មវិធី «មិត្តរបស់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (Friends of ARMAC)» ដែលបានរៀបចំនាពេលថ្មីៗនេះ នៅរាជធានីភ្នំពេញ ដើម្បីគាំទ្រដល់សកម្មភាពនានារបស់មជ្ឈមណ្ឌលចំពោះទិដ្ឋភាពមនុស្សធម៌ក្នុងការបោសសម្អាតមីន។

**ឯកឧត្តម** ក៏បានសម្តែងនូវ ការព្រួយបារម្ភអំពីសុវត្ថិភាពការងារ និងសុខុមាលភាពរបស់ពលករចំណាកស្រុកដែលកំពុងតែធ្វើការ នៅក្នុងតំបន់ ហើយបានគូសបញ្ជាក់នូវការគាំទ្ររបស់កម្ពុជាចំពោះអនុសាសន៍របស់វេទិកាអាស៊ាន ស្តីពីការងារពលករចំណាកស្រុកលើកទី១៤ (14th AFML) ដើម្បីផ្តល់ការការពារផ្នែកសង្គមកិច្ចដល់ពលករចំណាកស្រុក និងកៀងគរការគាំទ្រជាអន្តរជាតិសម្រាប់កម្មវិធីបណ្តុះបណ្តាលបន្ត និង ជំនាញថ្មី (upskill and reskill)។

**កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ានលើកទី៣០ (30th ACC)**

រដ្ឋមន្ត្រីការបរទេសអាស៊ានបានផ្លាស់ប្តូរទស្សនៈគ្នាលើគំនិតផ្តួចផ្តើមសំខាន់ៗរបស់អាស៊ានក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ជាពិសេសក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (ACRF) ការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់ភាពបន្ទាន់ផ្នែកសុខភាពសាធារណៈ និងជំងឺដែលកំពុងកើតមាន (ACPHEED) និងការបម្រុងសម្ភារៈវេជ្ជសាស្ត្រសម្រាប់ភាពបន្ទាន់ផ្នែកសុខភាពសាធារណៈក្នុងតំបន់អាស៊ាន (ARRMS) ក្នុងចំណោមគំនិតផ្តួចផ្តើមផ្សេងៗទៀត។

រដ្ឋមន្ត្រីអាស៊ានបានឯកភាពដាក់ចេញនូវធនធានបន្ថែមទៀត ដើម្បីឆ្ពោះទៅសម្រេចបាននូវការអនុវត្តគំនិតផ្តួចផ្តើមទាំងនេះឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ រដ្ឋមន្ត្រីបានចែករំលែកទស្សនៈអំពីតម្រូវការចាំបាច់ក្នុងការពន្លឿនកិច្ចការអាទិភាព ដូចជាការបើកឡើងវិញនៃការធ្វើដំណើរឆ្លងដែនប្រកបដោយសុវត្ថិភាពនិងទំនុកចិត្តនៅក្នុងតំបន់ ការបង្កើនការតភ្ជាប់ សេដ្ឋកិច្ចឌីជីថល និងនវានុវត្តន៍។

រដ្ឋមន្ត្រីបានទទួលស្គាល់ថា ក្របខ័ណ្ឌការរៀបចំច្រករបៀងធ្វើដំណើរក្នុងតំបន់អាស៊ាន (ATCAF) និងការបម្រុងសម្ភារៈវេជ្ជសាស្ត្រសម្រាប់ភាពបន្ទាន់ផ្នែកសុខភាពសាធារណៈក្នុងតំបន់អាស៊ាន (ARRMS) ពិតជាមានសារៈសំខាន់សម្រាប់ប្រែក្លាយតំបន់ឱ្យវិលត្រឡប់ទៅរកប្រក្រតីភាពជាបណ្តើរៗឡើងវិញ និងដើម្បីបង្កើនការត្រៀមខ្លួនរបស់អាស៊ានសម្រាប់វិបត្តិសុខភាពក្នុងតំបន់នាពេល អនាគត។ ក្នុងន័យនេះ រដ្ឋមន្ត្រីបានលើកទឹកចិត្តឱ្យគំនិតផ្តួចផ្តើមទាំងពីរនេះឆាប់មានដំណើរការ។

នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការពេញចិត្តចំពោះវឌ្ឍនភាពនៃការអនុវត្ត ACRF និងបានបញ្ជាក់ជាថ្មីអំពីសារៈសំខាន់នៃក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព ក៏ដូចជាគោលការណ៍ណែនាំសម្រាប់ការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗ និងដៃគូខាងក្រៅដែលមានបំណងគាំទ្រក្របខ័ណ្ឌនេះ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជំរុញឱ្យបញ្ចប់បានឆាប់នូវការជ្រើសរើសប្រទេសជាម្ចាស់ផ្ទះ និងការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់ភាពបន្ទាន់ផ្នែកសុខភាពសាធារណៈ និងជំងឺដែលកំពុងកើតមាន (ACPHEED) ដើម្បីរួមចំណែកដល់ការពង្រឹងប្រព័ន្ធសុខាភិបាល ក្នុងតំបន់ ដែលជាវិស័យចម្បងក្នុងចំណោមវិស័យយុទ្ធសាស្ត្រធំៗទាំង៥ នៃក្របខ័ណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន (ACRF)។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការអនុវត្តក្របខ័ណ្ឌការរៀបចំច្រករបៀងធ្វើដំណើរក្នុងតំបន់អាស៊ាន (ATCAF) ដើម្បីអនុញ្ញាតឱ្យសកម្មភាពធ្វើដំណើរ និងអាជីវកម្មនៅទូទាំងតំបន់វិលត្រឡប់មករកប្រក្រតីភាពឡើងវិញជាបណ្តើរៗ ដោយមិនប៉ះពាល់ដល់សុវត្ថិភាពសុខភាពសាធារណៈ ហើយ**ឯកឧត្តម**ទន្ទឹងរង់ចាំការបង្កើតឱ្យបានឆាប់នូវក្រុមការងារអចិន្ត្រៃយ៍ ដើម្បីចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន។

ចំពោះសំណើចូលជាសមាជិកអាស៊ានរបស់ទីម័រឡេស្ត **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីអំពីការគាំទ្ររបស់កម្ពុជាចំពោះសំណើរបស់ទីម័រឡេស្ត ហើយបានលើកទឹកចិត្តដល់សសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន ពន្លឿនបេសកកម្មស្វែងរកការពិតរបស់ខ្លួន ដើម្បីអាចឱ្យអាស៊ានបង្កើតផែនទីបង្ហាញផ្លូវ និងកាលវិភាគសមស្របសម្រាប់ប្រទេសទីម័រឡេស្តចូលជាសមាជិកអាស៊ាន។ **ឯកឧត្តម** ក៏បានសម្តែងការគាំទ្រឱ្យមានទំនាក់ទំនងបន្ថែមទៀតជាមួយប្រទេសទីម័រឡេស្ត ក្នុងកម្មវិធីពង្រឹងសមត្ថភាពផ្សេងៗដែលស្ថិតក្នុងក្របខ័ណ្ឌអាស៊ាន។

រដ្ឋមន្ត្រីការបរទេសអាស៊ាន ក៏បានពិភាក្សាផងដែរអំពីការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៨ និងទី៣៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលគ្រោងនឹងប្រព្រឹត្តទៅពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២១ ខាងមុខនេះ។

## កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM)

កិច្ចប្រជុំបានពិភាក្សាលើបញ្ហាសំខាន់ៗមួយចំនួន រួមមានកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសហគមន៍អាស៊ាន ទិដ្ឋភាពនយោបាយ និងសន្តិសុខ បញ្ហានានាពាក់ព័ន្ធនឹងទំនាក់ទំនងខាងក្រៅ ក៏ដូចជាបញ្ហាតំបន់ និងអន្តរជាតិបន្ទាន់ផ្សេងៗទៀត ដែលជាចំណាប់អារម្មណ៍ និងកង្វល់រួម។

រដ្ឋមន្ត្រីការបរទេសអាស៊ាន បានស្វាគមន៍ចំពោះវឌ្ឍនភាពនៅក្នុងការសម្រេចបានសមិទ្ធផលសំខាន់ៗរបស់អាស៊ានក្នុងឆ្នាំ២០២១ និងទន្ទឹងរង់ចាំចំពោះការអនុម័តនូវសមិទ្ធផលទាំងនេះ ដោយថ្នាក់ដឹកនាំអាស៊ាននៅក្នុងកិច្ចប្រជុំកំពូលអាស៊ាននាពេលខាងមុខ។

កិច្ចប្រជុំបានផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកលើការពង្រឹង និងពង្រីកការចូលរួមប្រកបដោយការស្ថាបនាជាមួយដៃគូខាងក្រៅអាស៊ាន។ កិច្ចប្រជុំបានឯកភាពគ្នាលើការចាប់ផ្តើមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន-ចក្រភពអង់គ្លេស និងការរៀបចំផែនការសកម្មភាពអាស៊ាន-ចក្រភពអង់គ្លេស រយៈពេល៥ឆ្នាំ។ អង្គប្រជុំបានឯកភាពថា ប្រទេសព្រុយណេដារ៉ូស្សាឡាម នឹងធ្វើជាប្រទេសសម្របសម្រួលដំបូងសម្រាប់ទំនាក់ទំនងសន្ទនាអាស៊ាន-ចក្រភពអង់គ្លេស ឆ្នាំ២០២១-២០២៤។ កិច្ចប្រជុំក៏បានឯកភាពលើសំណើរបស់ប្រទេសចិននិងរុស្ស៊ី ដើម្បីរំលឹកខួបលើកទី៣០ នៃទំនាក់ទំនងអាស៊ាន-ចិន និងអាស៊ាន-រុស្ស៊ី នៅឆ្នាំនេះ។

កិច្ចប្រជុំក៏បានផ្លាស់ប្តូរទស្សនៈគ្នាផងដែរលើបញ្ហាតំបន់និងអន្តរជាតិនានា ហើយបានបញ្ជាក់ជាថ្មីនូវបំណងប្រាថ្នារួមក្នុងការរក្សាស្មារតីនៃតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត្យ (ZOPFAN) សន្ធិសញ្ញាស្តីពីតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ) ការរំសាយអាវុធនុយក្លេអ៊ែរ នៅក្នុងបរិបទនៃនិម្មាបនកម្មតំបន់ដែលមានការវិវត្ត ដែលត្រូវបានរារាំងដោយការប្រកួតប្រជែងនិងភាពតានតឹងរវាងប្រទេសមហាអំណាច។

រដ្ឋមន្ត្រីបានពិភាក្សាអំពីមធ្យោបាយ ដើម្បីពន្លឿនការផ្តល់ជំនួយមនុស្សធម៌របស់អាស៊ានប្រកបដោយភាពរលូនទៅកាន់ប្រទេសមីយ៉ាន់ម៉ា និងបានសង្កត់ធ្ងន់លើតម្រូវការបន្ទាន់ដើម្បីសម្រេចបានវឌ្ឍនភាពក្នុងការអនុវត្ត**ការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុចរបស់ថ្នាក់ដឹកនាំអាស៊ាន** មិនមែនត្រឹមតែជាការផ្តល់ជំនួយសង្គ្រោះនោះទេ។

នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរដល់ប្រទេសព្រុយណេដារ៉ូស្សាឡាម ដែលបានដឹកនាំធ្វើជាប្រធានអាស៊ានឆ្នាំ២០២១ សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន។ ចំពោះទំនាក់ទំនងខាងក្រៅ ក្នុងនាមកម្ពុជាជាប្រទេសសម្របសម្រួលទំនាក់ទំនងអាស៊ាន-រុស្ស៊ី **ឯកឧត្តម** បានជម្រាបជូនអង្គប្រជុំអំពីកិច្ចប្រជុំកំពូលអាស៊ាន-រុស្ស៊ីលើកទី៤ នាពេលខាងមុខ និងឯកសារលទ្ធផលសំខាន់ៗនៃកិច្ចប្រជុំកំពូលនេះ។ **ឯកឧត្តម** ក៏បានបញ្ជាក់ជាថ្មីពីការគាំទ្ររបស់កម្ពុជាចំពោះសំណើបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ទាំងជាមួយប្រទេសចិន និងអូស្ត្រាលី។

ចំពោះបញ្ហាតំបន់និងអន្តរជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការព្រួយបារម្ភអំពីការកើនឡើងភាពតានតឹងភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងរវាងមហាអំណាច ដែលអាចបង្កអន្តរាយដល់ស្ថិរភាព សន្តិភាព និងសន្តិសុខក្នុងតំបន់។ **ឯកឧត្តម** បានបញ្ជាក់សាជាថ្មីពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់ចំពោះគោលបំណង និងគោលការណ៍ ដែលបានកំណត់ក្នុងធម្មនុញ្ញអាស៊ាន សន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) តំបន់សន្តិភាព សេរីភាព និងអព្យាក្រឹតភាព (ZOPFAN) សន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ) និងទស្សនវិស័យអាស៊ាន ស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) ។ ចំពោះបញ្ហាមីយ៉ាន់ម៉ា និងការអនុវត្តការព្រមព្រៀងជាឯកច្ឆ័ន្ទ៥ចំណុច **ឯកឧត្តម** ក៏បានចែករំលែកនូវបទពិសោធន៍ដ៏សំខាន់ៗ ស្តីពីដំណើរការរយៈពេលវែង និងជោគជ័យ នៃការស្វែងរកសន្តិភាព និងការផ្សះផ្សាជាតិនៅកម្ពុជា។

ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនអង្គប្រជុំផងដែរអំពីកាលវិភាគ និងការរៀបចំបឋម សម្រាប់ព្រឹត្តិការណ៍សំខាន់ៗមួយចំនួននៅឆ្នាំក្រោយ៕

ថ្ងៃអង្គារ ១៤ រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១